PESTECH

# ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

# របាយការណ៍ប្រចាំត្រីមាស

## ត្រីមាសទី ១ សម្រាប់ឆ្នាំហិរញ្ញវត្ថុ

## ដែលបានបញ្ចប់នៅ

## ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២១

PESTECH

# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទី១ ឆ្នាំ ២០២២ (លានរៀល) | ឆ្នាំ ២០២១ (លានរៀល) | ឆ្នាំ ២០២០ (លានរៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១ ១៩១ ៧៨៩ | ១ ១៦៦ ៨៤២ | ១ ០១៦ ១១២ |
| បំណុលសរុប | | ១ ០៩១ ៥៨១ | ១ ០៧២ ៩៨៥ | ៩៤៦ ១៥៥ |
| មូលធនសរុប | | ១០០ ២០៨ | ៩៣ ៨៩៧ | ៦៩ ៩៥៧ |
| **ចំណេញ/ (ខាត)** | | **ត្រីមាសទី១ ឆ្នាំ ២០២២ (លានរៀល)** | **ត្រីមាសទីមួយ ឆ្នាំ ២០២១ (លានរៀល)** | **ត្រីមាសទីមួយ ឆ្នាំ ២០២០ (លានរៀល)** |
| ចំណូលសរុប | | ៧៤ ១៥៧ | ៧៤ ៤៤៨ | ៤២ ៧០៩ |
| ចំណេញមុនបង់ពន្ធ | | ៥ ៤៨៧ | (១៨៨) | ១ ៨២២ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | ៤ ៤៦៨ | (១ ២៩៥) | ៦២០ |
| ចំណេញ/(ខាត)សរុបលម្អិត | | ៦ ៣១១ | (៦៤៤) | (៤ ៥២១) |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទីមួយ ឆ្នាំ ២០២២** | **ឆ្នាំ ២០២១** | **ឆ្នាំ ២០២០** |
| អនុបាតសាធនភាព | | ១,៣៧% | ២,៤០% | ៧,៤៣% |
| អនុបាតសាធនភាព (ប្រាក់កម្ចីទូទៅ)* | | ៣៩,៥៨% | ៤៩,៩៣% | ២០៣,៨៧% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៩២ | ០,៩០ | ០,២៨ |
| | អនុបាតចរន្តលឿន | ០,៩០ | ០,៨៨ | ០,២៤ |
| | | **ត្រីមាសទីមួយ ឆ្នាំ ២០២២** | **ត្រីមាសទីមួយ ឆ្នាំ ២០២១** | **ត្រីមាសទីមួយ ឆ្នាំ ២០២០** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | ០,៣៧% | (០,១២%) | ០,០៦% |
| | អនុបាតចំណេញធៀបនឹងមូលធន | ៤,៤៦% | (១,៥៩%) | ០,៨៩% |
| | អនុបាតគម្លាតចំណេញដុល | ១៤,៧៩% | ១៣,៤៣% | ៧,៣៥% |
| | អនុបាតគម្លាតចំណេញភាព | ៦,០៣% | (១,៧៤%) | ១,៤៥% |
| | ចំណេញក្នុងមួយឯកតាមូលបត្រ កម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) (រៀល) | ៥៩,៦២ | (១៧,៥៥) | ៨,៧៣ |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | ១,៤៦ | ០,៩៧ | ១,៤០ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិន មាន) (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | | គ្មាន | គ្មាន | គ្មាន |

*កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គីសនីកម្ពុជា។ កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមានចំនួន ១៤ ៣០៥ លានរៀល (ឆ្នាំ២០២១៖ ២០ ៥៥៤ លានរៀល) និងកម្ចីរយៈពេលវែងមានចំនួន ៤០០ ០៤៨ លានរៀល គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ (ឆ្នាំ ២០២១៖ ៤០៧ ៨០៦ លានរៀល)។

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



PESTECH

# មតិរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគហ៊ុនិក

យើងខ្ញុំមានសេចក្តីរំភើបរីករាយចំពោះការស្វាគមន៍ឆ្នាំហិរញ្ញវត្ថុ ("FY") ២០២២ ជាមួយនឹងទស្សនវិស័យដ៏សម្បូរបែប និងការយកចិត្តទុកដាក់ប្រកបដោយសុទិដ្ឋិនិយម។

អំឡុងត្រីមាសទី ១ នៃឆ្នាំហិរញ្ញវត្ថុ ២០២២ សកម្មភាពអាជីវកម្មបានចាប់ផ្តើមដំណើរការជាធម្មតាខណៈពេលដែលមានការជម្រុញការចាក់វ៉ាក់សាំងយ៉ាងឆាប់រហ័សនៅក្នុងប្រទេស។ ការបើកដំណើរព្រំដែនឱ្យឆ្លងកាត់ត្រូវបានបន្ធូរបន្ថយជាបណ្តើរៗដោយការប្រកាន់ខ្ជាប់នូវនីតិវិធីប្រតិបត្តិការស្តង់ដារ ("SOP")។ ការបើកដំណើរព្រំដែនឱ្យឆ្លងកាត់នេះបានផ្តល់ឱកាសឱ្យមានលំហូរសហគមន៍អាជីវកម្មកាន់តែប្រសើរឡើង និងការផ្តល់ឱកាសឡើងវិញដល់ពាណិជ្ជកម្មឱ្យកាន់តែច្រើននៅក្នុងតំបន់។

ជាមួយនឹងក្រុមបុគ្គលិកស្ម័គ្រចិត្តដែលបានទទួលចាក់ថ្នាំបង្ការគ្រប់ចំនួន ទាំងបុគ្គលិកការិយាល័យ និងបុគ្គលិកការដ្ឋានបានទទួលកាការពារយ៉ាងពេញលេញប្រឆាំងនឹងរោគសញ្ញានៃការឆ្លងមេរោគ កូវីដ-១៩ ធ្ងន់ធ្ងរដែលជាមូលហេតុបានសម្រួលដល់ពួកគេអាចបំពេញការងារដោយស្ងប់ចិត្តសម្រាប់ខ្លួនគេផ្ទាល់ និងក្រុមគ្រួសារ។

ក្រុមហ៊ុនបានខិតខំលើការផ្តល់នូវគម្រោងវិជ្ជមាន និងការអនុវត្តផ្នែកហិរញ្ញវត្ថុដែលបង្ហាញនូវលទ្ធផលក្នុងត្រីមាសទី១ ហើយក៏ដូចជាការបន្តផ្តោតលើចក្ខុវិស័យរបស់ខ្លួនក្នុងការកសាងអង្គភាពសាជីវកម្មឈានមុខប្រកបដោយនិរន្តរភាពខាងផ្នែកថាមពលកកើតឡើងវិញ បច្ចេកវិទ្យាស្មាត ស្វ័យប្រវត្តិកម្ម និងឧស្សាហកម្មអ៊ីនធឺណិតស្របតាមទំនើបកម្មយ៉ាងឆាប់រហ័សនៅប្រទេសកម្ពុជា។

យើងខ្ញុំសង្ឃឹមថានឹងអាចជួយនាំយកនូវបច្ចេកវិទ្យាបៃតង ដែលជាផ្នែកមួយនៃបែបផែននៃការរស់នៅក្នុងសហគមន៍នៃប្រទេសកម្ពុជា តាមរយៈការផ្សព្វផ្សាយពីយានជំនិះដែលបញ្ចូលថាមពលអគ្គិសនី ការប្រើប្រាស់បច្ចេកវិទ្យាអគ្គិសនីឆ្លាតវៃសម្រាប់គ្រប់គ្រងអគារ និងការកែច្នៃកាកសំណល់ឱ្យទៅជាថាមពល។ បន្ថែមពីលើការផលិតថាមពលពន្លឺព្រះអាទិត្យដែលបានអនុវត្តយ៉ាងទូលំទូលាយនាពេលបច្ចុប្បន្នក្នុងការគាំទ្រផលិតកម្មថាមពលបៃតង PCL មានបំណងពង្រីកនូវតម្លៃបន្ថែមដែលអាចនាំមកនូវផលជាវិជ្ជមានដល់ជីវភាពរស់នៅប្រកបដោយនិរន្តរភាពរយៈពេលវែងរបស់សហគមន៍កម្ពុជា។

យើងបានបន្តលះបង់ប្តេជ្ញាចិត្តដោយឥតបែងចែកដើម្បីភាពរីកចម្រើនរបស់ ផថខ ខណៈពេលដែលយើងចងចាំពីការរួមចំណែកជាវិជ្ជមានស្របពេលដែលយើងត្រូវនាំមកនូវការកសាងហេដ្ឋារចនាសម្ព័ន្ធថាមពលឆ្ពោះទៅរកភាពរុងរឿងទាំងមូលនៃកម្ពុជា។ កាលណាប្រទេសរីកចម្រើន យើងនឹងរីកចម្រើនជាមួយគ្នាដែរ!

អរគុណ

PAUL LIM PAY CHUAN

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១

PESTECH

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

ភាគហ៊ុនិកជាទីរាប់អាន

យើងខ្ញុំរីករាយក្នុងការធ្វើបទបង្ហាញជូនលោកអ្នកនូវលទ្ធផលប្រចាំត្រីមាសទី ១ សម្រាប់ឆ្នាំហិរញ្ញវត្ថុ ("FY") ២០២២។

ប្រាក់ចំណូលសម្ព័ន្ធក្រុមហ៊ុនបានកត់ត្រាលទ្ធផលស្មើរតែដូចគ្នាទៅនឹងចំនួន ៧៤ ១៥៧ លានរៀល នៅក្នុងត្រីមាសទី ១ នៃឆ្នាំហិរញ្ញវត្ថុ ២០២២ បើប្រៀបធៀបទៅនឹងត្រីមាសទី ១ នៃឆ្នាំហិរញ្ញវត្ថុ ២០២១។ ប្រាក់ចំណេញប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុនបានកត់ត្រាកំណើនជាវិជ្ជមានពី ៦ ៧៨៦ លានរៀលដល់ ៧ ៨៤៨ លានរៀល។ ប្រាក់ចំណេញរបស់សម្ព័ន្ធក្រុមហ៊ុនជាលទ្ធផលបានបង្ហាញពីដំណើរការផ្លាស់ប្តូរយ៉ាងល្អប្រសើរ ចំនួន ៤ ៤៦៨ លានរៀល ក្នុងត្រីមាសទី ១ នៃឆ្នាំហិរញ្ញវត្ថុ ២០២២ ធៀបនឹងអវិជ្ជមានចំនួន ១ ២៩៥ លានរៀលក្នុងត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២១។

អនុបាតចរន្ត និងអនុបាតសន្ទនីយភាពទាំងពីររបស់សម្ព័ន្ធក្រុមហ៊ុនបានប្រសើរឡើងដល់ ០,៩២ និង ០,៩០ ដោយឡែកពីគ្នា។ សូចនាករទាំងនេះបានបង្ហាញថា ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្ព័ន្ធកំពុងអភិវឌ្ឍន៍ជាវិជ្ជមានក្នុងស្ថានភាពល្អប្រសើរ។ ក្នុងអំឡុងត្រីមាសទី ១ ផលចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតចំណេញធៀបនឹងមូលធនទាំងពីរត្រូវបានកត់ត្រាអនុបាតវិជ្ជមានខាងក្រោយនៃកំណើនប្រាក់ចំណេញដែលបានកើនឡើងចំនួន ១៤,៧៩%។ ការកើនឡើងនៃប្រាក់ចំណេញបានជួយជំរុញឱ្យអនុបាតលទ្ធភាពសងការប្រាក់កើនឡើងដល់ ១,៤៦ ដង ក្នុងត្រីមាសទី ១ នៃឆ្នាំហិរញ្ញវត្ថុ ២០២២ ។

តាមរយៈប្រតិបត្តិការនេះ យើងបានស្ថិតនៅក្នុងការអនុវត្តដំណាក់ចុងក្រោយនៃរោងចក្រថាមពលពន្លឺព្រះអាទិត្យខ្នាតធំ ២០ មេហ្គាវ៉ាត់ ដែលមានទីតាំងនៅក្នុងក្រុងបាវិត ចំណែកបន្ទះស្រូបថាមពលព្រះអាទិត្យ (photovoltaic) ត្រូវបានដំឡើងរួចរាល់ទាំងស្រុង ចំណែកឧបករណ៍ និងសមាសធាតុនឹងត្រូវសម្រេចជាស្ថាពរក្នុងអំឡុងត្រីមាសនេះ។ ដោយរង់ចាំការចែកចាយឧបករណ៍បំលែង និងឧបករណ៍ប្តូរ (switchgears) យើងបានប្តេជ្ញាឆ្ពោះទៅរកការដាក់រោងចក្រឱ្យដំណើរការក្នុងរយៈពេលដ៏ខ្លីបំផុតតាមដែលអាចធ្វើទៅបាន។

គម្រោងខ្សែបញ្ជូនដែលមានប្រវែង ១៣០គីឡូម៉ែត្រ សៀមរាមខាងកើត-ឧត្តរមានជ័យ កំពុងដំណើរការយ៉ាងសកម្មដោយការបញ្ជាទិញសម្ភារៈ និងការសាងសង់ប៉មបញ្ជូនកំពុងត្រូវបានពន្លឿនដើម្បីធានាថាយើងអនុវត្តទាន់ពេលវេលាចំពោះការដាក់ខ្សែបញ្ជូន និងកាលវិភាគបញ្ចប់ការងារ។

យើងខ្ញុំជឿជាក់ថា ការលះបង់របស់ក្រុមការងារដែលសមត្ថភាពនៅក្នុងស្រុក និងការគាំទ្រពីអតិថិជនដ៏ឆ្លាតវៃ យើងខ្ញុំនឹងអាចផ្តល់ជូននូវលទ្ធផលអនុវត្តគម្រោងប្រកបដោយភាពវិជ្ជមាន និងជោគជ័យជាបន្តបន្ទាប់សម្រាប់ភាគីពាក់ព័ន្ធទាំងអស់របស់យើង។

សូមអរគុណ

HAN FATT JUAN

**ប្រធាននាយកប្រតិបត្តិ**

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១

PESTECH

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

សមាសភាពក្រុមប្រឹក្សាភិបាល ........ iii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ iv

សេចក្តីថ្លែងប្រធាននាយកប្រតិបត្តិ ........ v

**ផ្នែកទី១៖ ព័ត៌មានទូទៅនៃក្រុមហ៊ុន ចុះបញ្ជី**

ក. អត្តសញ្ញាណក្រុមហ៊ុនចុះបញ្ជី
ខ. សកម្មភាពអាជីវកម្ម
គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី២៖ ព័ត៌មានពីលទ្ធផលប្រតិបត្តិការអាជីវកម្ម**

ក. លទ្ធផលប្រតិបត្តិការជីវកម្ម
ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្រឡើងវិញដោយសវនកឯករាជ្យ**

**ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ
ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ
គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល
ឃ. ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ
ង. ផលប៉ះពាល់នៃអតិផរណា
ច. សេដ្ឋកិច្ច សារពើពន្ធ គោលនយោបាយរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

**ផ្នែកទី៥៖ ព័ត៌មានសំខាន់ៗដ៏ទៃផ្សេងទៀតសម្រាប់ការការពារវិនិយោគិន**

ហត្ថលេខារបស់អភិបាលនៃក្រុមហ៊ុនចុះបញ្ជី

## ផ្នែកទី១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | **ផេសថិក (ខេមបូឌា) ម.ក** |
| ជាអក្សរឡាតាំង | PESTECH (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH១០០០១៥០០០៩ |
| និមិត្តសញ្ញា | ផថខ |
| អាសយដ្ឋាន | ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨ សង្កាត់បឹងកក់ទី II ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៨៨២ ១០៥ |
| លេខទូរសារ | +៨៥៥ ២៣ ៨៨២ ១០៦ |
| គេហទំព័រ | www.pestech.com.kh |
| អ៊ីមែល៖ | |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០០៩៥៧ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ៣២៦ ប្រក.ជនស.អសណ ចេញដោយ ជនស ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ |
| សេចក្តីសម្រេចអនុញ្ញាត្ត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៧១/២០ គ.ម.គ/ស.ស.រ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជានិយ័តករមូលបត្រកម្ពុជា "នមក") |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Paul Lim Pay Chuan |

### ខ. ប្រភេទអាជីវកម្ម

ផថខ បានរួមចំណែកជាចម្បងក្នុងការផ្តល់ វិស័យវិស្វកម្ម និងដំណោះស្រាយបច្ចេកទេសនៃប្រព័ន្ធអគ្គីសនីដ៏ទូលំទូលាយសម្រាប់៖

- ការរចនាប្លង់ លទ្ធកម្ម សាងសង់ តម្លើង និងការដាក់ឱ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គីសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គីសនីក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គីសនីផងដែរ
- កិច្ចដំណើរការ និងការថែទាំ ("**O&M**") ខ្សែបញ្ជូនអគ្គីសនី និងអនុស្ថានីយ៍ និង
- ការធ្វើពាណិជ្ជកម្ម បរិក្ខារប្រព័ន្ធអគ្គីសនី និងឧបករណ៍ ជាកម្មសិទ្ធិ និងមិនមែនជាកម្មសិទ្ធិ

### គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលបានកំណត់ភាគលាភចំនួន ០,០០៦៥ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

PESTECH

## ផ្នែកទី២៖ ព័ត៌មានអំពីលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម

### ក. លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

កិច្ចសន្យាលើវិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាសដែលមានទឹកប្រាក់ចំនួន ៧០ ៩៥៦ លានរៀល (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៧១ ២៣៨ លានរៀល) ដែលស្មើនឹងប្រមាណ ៩៥,៧% (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៩៥,៧%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសេវាថែទាំដែលស្មើនឹងប្រមាណ ៣ ២០១ លានរៀល ឬ ៤,៣% នៃចំណូលសរុប (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៣ ២១០ លានរៀល ឬ ៤,៣%)។ ប្រតិបត្តិការ និងថែទាំ ("O&M") គិតជាដុល្លារអាមេរិក ផ្អែកលើកិច្ចសន្យា O&M មានចំនួន ៧៨៥ ០០០ ដុល្លារអាមេរិកជារៀងរាល់ត្រីមាស។

ក្នុងកំឡុងត្រីមាសនេះ យើងបានទទួលស្គាល់ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យាមានចំនួន ២ ៩៨៤ លានរៀល។ ចំណូលហិរញ្ញប្បទានបានមកពីការអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ១៥ ("CIFRS") 15 សម្រាប់គម្រោងមួយចំនួនរបស់យើង ហើយវាគឺជាផ្នែកមួយនៃប្រាក់ចំណូលសរុបរបស់យើងនៅក្នុងសម្ព័ន្ធ។

### ខ. វិចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២២ | | ត្រីមាសទី១ ឆ្នាំ២០២១ | | ត្រីមាសទី១ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ("EPCC) កិច្ចសន្យាសម្រាប់អគ្គីសនី និងអនុស្ថានីយ៍ | ៧០ ៩៥៦ | ៩៥,៧ | ៧១ ២៣៨ | ៩៥,៧ | ៤០ ៨៧៥ | ៩៥,៧ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ៣ ២០១ | ៤,៣ | ៣ ២១០ | ៤,៣ | ១ ៨៣៤ | ៤,៣ |
| | **ប្រាក់ចំណូលសរុប** | **៧៤ ១៥៧** | **១០០,០** | **៧៤ ៤៤៨** | **១០០,០** | **៤២ ៧០៩** | **១០០,០** |
| ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យា | | ២ ៩៨៤ | ១០០,០ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| | **ប្រាក់ចំណូលសរុប** | **៧៧ ១៤១** | **១០០,០** | **៧៤ ៤៤៨** | **១០០,០** | **៤២ ៧០៩** | **១០០,០** |

PESTECH

## ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុពិនិត្យដោយសវនករខាងក្រៅ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយត្រូវបានធ្វើការត្រួតពិនិត្រឡើងវិញរួចរាល់ហើយ ដោយសវនករឯករាជ្យ។

PESTECH

## ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង ("MD&A")

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២១ បានកត់ត្រាត្រឹម ៧៤ ១៥៧ លានរៀល ដែលតំណាងឱ្យវឌ្ឍនភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ចំណូលសរុបដែលត្រូវបានកត់ត្រាដោយប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។ ប្រាក់ចំណូលដែលត្រូវបានរាយការណ៍ជាប្រាក់រៀល មានកម្រិតទាបជាងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយសារបម្រែបម្រួលនៃអត្រាប្តូរប្រាក់។

### ២. ការវិភាគចំណូលតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាស ដែលមានទឹកប្រាក់ចំនួន ៧០ ៩៥៦ លានរៀល (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៧១ ២៣៨ លានរៀល) ដែលស្មើនឹងប្រមាណ ៩៥,៧% (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៩៥,៧%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសេវាថែទាំ ដែលស្មើនឹងប្រមាណ ៣ ២០១ លានរៀល ឬ ៤,៣% នៃចំណូលសរុប (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៣ ២១០ លានរៀល ឬ ៤,៣%)។ ប្រតិបត្តិការ និងថែទាំ ("O&M") គិតជាដុល្លារអាមេរិក ផ្អែកលើកិច្ចសន្យា O&M មានចំនួន ៧៨៥ ០០០ ដុល្លារអាមេរិក ជារៀងរាល់ត្រីមាស។

### ៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ១៤,៨% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន មានចំនួន ១៣,៤% ដោយកើនឡើងចំនួន ១,៤%។ ចំណេញដុលក្នុងត្រីមាសបច្ចុប្បន្ន គឺស្ថិតក្នុងការរំពឹងទុករបស់យើងខ្ញុំ។

### ៤. ការវិភាគចំណេញមុនបង់ពន្ធ

ចំណេញមុនបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ៥ ៤៨៧ លានរៀល បើប្រៀបធៀបទៅនឹងការខាតមុនពេលបង់ពន្ធមានចំនួន ១៨៨ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយកើនឡើងចំនួន ៥ ៦៧៥ លានរៀល ឬ ៣ ០១៨,៦% ។ ការកើនឡើងនេះ ត្រូវបានរួមចំណែកជាចម្បងដោយការទទួលស្គាល់ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យាដែលមានចំនួន ២ ៩៨៤ លានរៀល (ត្រីមាសទីមួយ ឆ្នាំ ២០២១៖ គ្មាន) និង ចំណាយហិរញ្ញប្បទានទាបដោយសារតែការសងប្រាក់កម្ចីរយៈពេលវែងដែលចាប់ផ្តើម ឆ្នាំ២០២០។

PESTECH

### ៥. ការវិភាគចំណេញក្នុងការិយបរិច្ឆេទ

លទ្ធផលនៃត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញមានចំនួនត្រឹម ៤ ៤៦៨ លានរៀល បើប្រៀបធៀបទៅនឹងការខាតក្រោយដកពន្ធមានចំនួន ១ ២៩៥ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយកើនឡើងមានចំនួន ៥ ៧៦៣ លានរៀល ឬ ៤៤៥,០%។

### ខ. កត្តាសំខាន់ដែលជះឥទ្ធិពលលើប្រាក់ចំណេញ

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញនេះ មិនមានកត្តាសំខាន់ៗណាមួយដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់ប្រតិបត្តិការចំពោះសម្ព័ន្ធក្រុមហ៊ុនឡើយ។

### គ. ការប្រែប្រួលសំខាន់ៗនៃការលក់ និងប្រាក់ចំណេញ

ពុំមានការផ្លាស់ប្តូរសំខាន់ៗក្នុងការលក់ និងប្រាក់ចំណូលទេ ដោយមានការប្រែប្រួលត្រឹមតែ ០,៤% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

### ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងតម្លៃទំនិញ

ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងការឡើងចុះនៃតម្លៃទំនិញនោះទេ។

### ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើង គឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ១០% នៃចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជា មានចំនួន ៣,០% (គិតត្រឹមថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២១ ប្រភព៖ *សេចក្តីប្រកាសព័ត៌មានលេខ ២១/២៧៦ បុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) បំពេញបេសកកម្មនៃមាត្រាទីបួនឆ្នាំ 2021 មកកាន់ប្រទេសកម្ពុជា)* ដែលបានបង្កផលប៉ះពាល់ប្រហែល ០,៣% ប៉ុណ្ណោះ ចំពោះប្រាក់ចំណេញរបស់យើង ។ រាល់ចំណាយប្រតិបត្តិការទាំងអស់មានតម្លៃថេរនៅក្នុងរយៈពេលនៃកិច្ចសន្យាទាំងមូល។ ក្រៅពីការលើកឡើងខាងលើនេះ ពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀតដែលបណ្តាលមកពីអតិផរណានោះទេ។

### ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ រូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុនៅក្នុងអំឡុងឆ្នាំនេះនោះទេ។

## ផ្នែកទី ៥៖ ព័ត៌មានសំខាន់ៗដទៃទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥

ថ្ងៃទី ១១ វិច្ឆិកា ២០២១

បានអាន និងឯកភាព

**ហត្ថលេខា**

PAUL LIM PAY CHUAN

ប្រធានក្រុមប្រឹក្សាភិបាល